## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**
លេខ ៨២១.កយ.អរណ/០៦

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

<u>ជម្រាបមក</u>

## លោក លោកស្រី ប្រធានតុលាការគ្រប់ខេត្ត ក្រុង

**<u>កម្មវត្ថុ:</u>** អំពីសំណើសុំអន្តរាគមន៍ទៅស្ថាប័នតុលាការឱ្យជួយដោះស្រាយលើបំណុលពន្ធរដ្ឋរបស់ក្រុមហ៊ុនវិនិយោគនានា ដែលត្រូវបានបិទទ្វារតាមរយៈសាលក្រមរបស់តុលាការ ។

**<u>យោង:</u>** -លិខិតលេខ៩៦៩/០៦ ក.អ.ក ចុះថ្ងៃទី១៣-០៣-២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក-លោកស្រីប្រធានថា ក្រសួងយុត្តិធម៌បានទទួលលិខិតលេខ៩៦៩/០៦ ក.អ.ក ចុះថ្ងៃទី១៣-០៣-២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលសុំក្រសួងឱ្យជួយអន្តរាគមន៍ដូចមាននៅក្នុងកម្មវត្ថុខាងលើ ។

នៅក្នុងលិខិតបានបញ្ជាក់ថា រយៈពេលកន្លងមកក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសង្កេតឃើញថា មានក្រុមហ៊ុនវិនិយោគមួយចំនួនបានបិទទ្វារតាមផ្លូវតុលាការ ។ តុលាការបានចេញសាលក្រមរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងដើម្បីទូទាត់បំណុលនានាដែលក្នុងនោះតុលាការពុំបានរំលឹកពីការទូទាត់បំណុលពន្ធរដ្ឋទេ ។

ក្នុងករណីខាងលើនេះ ជាគោលការណ៍ ក្នុងនីតិវិធីរដ្ឋប្បវេណី តុលាការអាចសម្រេចលើករណីណាមួយបានលុះត្រាតែមានពាក្យបណ្តឹងសុំ ហេតុនេះក្នុងករណីមានក្រុមហ៊ុនណាមួយជំពាក់បំណុលរដ្ឋ សូមឱ្យមន្ត្រីដែលមានសមត្ថកិច្ច រៀបចំឯកសារ ប្តឹងចូលតុលាការ នោះទើបតុលាការអាចសម្រេចតាមផ្លូវច្បាប់បាន ។

អាស្រ័យហេតុនេះ ក្រសួងសូមឱ្យលោក-លោកស្រី ប្រធានតុលាការខេត្ត-ក្រុង គប្បីយកចិត្តទុកដាក់ផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៅពេលដែលតុលាការទទួលដោះស្រាយបញ្ហា បិទ ឬរំលាយក្រុមហ៊ុនតាមអំណាចសាលក្រម ដើម្បីឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចប្តឹងទារបំណុលពន្ធរដ្ឋពីក្រុមហ៊ុនដែលជំពាក់នោះ ។

សូមលោក-លោកស្រី ទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៥

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍនា**

<u>ចម្លងជូន</u>

-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ដើម្បីជូនជ្រាបជាព័ត៌មាន
-ឯកសារ -កាលប្បវត្តិ